ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សហគមន៍នេសាទក្តីឈ្វិត

ភូមិក្តីឈ្វិត ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់

គាំទ្រដោយអង្គការស្តារកម្ពុជា

ឧបត្ថម្ភដោយ

ឧបត្ថម្ភដោយ

ផ្កាយកម្ពុជា

STAR KAMPUCHEA

អង្គការហ្វរ៉ូមស៊ីដ

forum syd

អង្គការអ៊ីអ៊ីឌី

eed

Evangelischer Entwicklungsdienst

# មាតិកា


១. កិច្ចព្រមព្រៀងសហគមន៍នេសាទ

២. ផែនទីដែនសហគមន៍ និងដែនអភិរក្សសហគមន៍

៣. បញ្ជីឈ្មោះគណៈកម្មការ រចនាសម្ព័ន្ធ

៤. បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ

៥. លក្ខន្តិកៈសហគមន៍នេសាទ

៦. បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

៧. សេចក្តីថ្លែងការណ៍សហគមន៍នេសាទ

៨. ឯកសារផ្សេងៗដែលពាក់ព័ន្ធ

- លិខិតសុំចុះកិច្ចព្រមព្រៀង
- កំណត់ហេតុមហាសន្និបាត
- កំណត់ហេតុបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍
- និងកំណត់ហេតុប្រជុំនានា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងសហគមន៍នេសាទ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : សហគមន៍នេសាទក្តីឈ្វិត |
| ភូមិ | : ក្តីឈ្វិត |
| ឃុំ | : ស្រែស្តុក |
| ស្រុក | : កណ្តៀង |
| ខេត្ត | : ពោធិ៍សាត់ |

# កិច្ចព្រមព្រៀង
# កន្លែងនេសាទសហគមន៍

## រវាង

នាយខណ្ឌរដ្ឋបាលជលផល ពោធិ៍សាត់ ជាតំណាងស្របច្បាប់នៃរដ្ឋបាលជលផល មានអាស័យដ្ឋាននៅ : ភូមិពាលញែក២ សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ទូរស័ព្ទលេខ ០៥២ ៩៥១ ៤៩១ អ៊ីមែល songlypursat@online.com.kh ទូរសារលេខ ០៥២ ៩៥១ ៤៩១ ហៅថា " ភាគី **ក** " ។

## និង

ប្រធានគណៈកម្មការសហគមន៍នេសាទ **ក្តីឈ្វិត** ជាតំណាងស្របច្បាប់ឱ្យសហគមន៍នេសាទ ដែលមានអាស័យដ្ឋាន ស្ថិតនៅ :ភូមិក្តីឈ្វិត ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្ត ពោធិ៍សាត់ ទូរស័ព្ទលេខ ០៨៩ ៩៦៥ ៥០៤៧ ហៅថា "ភាគី **ខ** " ។

**ភាគីទាំងពីរបានឯកភាពគ្នាចុះកិច្ចព្រមព្រៀងតាមលក្ខខ័ណ្ឌដូចខាងក្រោម :**

**ប្រការ ១:** ភាគី **ក** ប្រគល់ដែននេសាទដែលជាទ្រព្យសម្បត្តិរបស់រដ្ឋឱ្យភាគី **ខ** ធ្វើការគ្រប់គ្រង ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលរយៈពេល ៣ ឆ្នាំ ។
ដោយគិតចាប់ពីថ្ងៃទី.........ខែ...............ឆ្នាំ............រហូតដល់ថ្ងៃទី........ខែ...............ឆ្នាំ............. ។
ដោយធានានូវចិរភាពតាមរយៈការរៀបចំសហគមន៍នេសាទ ។

**ប្រការ ២:** ដែននេសាទនេះមានឈ្មោះថា "កន្លែងនេសាទសហគមន៍ក្តីឈ្វិត " ដែលលាតសន្ធឹងនៅក្នុង :

ភូមិ ក្តីឈ្វិត ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់

មាននិយាមកាដូចខាងក្រោម :
GCP01( X: 393507, Y: 1406825) GCP02( X: 392565, Y: 1407028) GCP03( X: 393768, Y: 1407288) GCP04( X: 393845, Y: 1407789) GCP05( X: 395117, Y: 1409756) GCP06( X: 392923, Y: 1410556) GCP07 ( X: 392396, Y: 1409087) GCP08 ( X: 391763 , Y: 1408390) GCP09 ( X: 391131, Y: 1407001)
ដូចផែនទីដែលបានភ្ជាប់មកជាមួយ ។

**ប្រការ ៣:** ភាគី ក ត្រូវបំពេញភារកិច្ចជាអ្នកជួយសម្របសម្រួល ផ្តល់បច្ចេកទេស ទប់ស្កាត់បទល្មើសតាមដាននិងត្រួតពិនិត្យលើការរៀបចំនិងការប្រព្រឹត្តិទៅរបស់សហគមន៍នេសាទដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៧ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ។

**ប្រការ ៤:** ភាគី ខ ត្រូវរៀបចំ :

-កន្លែងអភិរក្សព្រៃលិចទឹក ត្រីមេពូជ និង រុក្ខជាតិទឹកផ្សេងទៀត

- ស្រះ អាង អន្លង់ត្រីមេពូជ
- កន្លែងអភិរក្សជីវៈចំរុះ
- ស្ថារប្រឡាយ ព្រែក បឹង ស្រះ
- ដាំព្រៃលិចទឹក
- ធ្វើវារីវប្បកម្ម
- បញ្ជូនសមាជិកសហគមន៍ដើម្បីរៀនសូត្រនូវបច្ចេកទេសផលិតពូជត្រី
- ការងារអភិវឌ្ឍន៍ផ្សេងៗទៀត ។

**ប្រការ ៥:** ភាគី ខ ត្រូវរៀបចំកិច្ចប្រជុំពិភាក្សាអំពីប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទដែលអនុញ្ញាតឱ្យប្រើប្រាស់ នៅក្នុងកន្លែងនេសាទសហគមន៍ ឱ្យសមស្របតាមស្ថានភាពភូមិសាស្ត្រ និងពេលវេលា ផ្អែកតាមច្បាប់ស្តីពីជលផល និងលិខិត បទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ ។

**ប្រការ ៦:** ភាគី ខ មានកាតព្វកិច្ចថែរក្សាការពារធនធានធម្មជាតិដូចខាងក្រោម :

- ការពារព្រៃលិចទឹកដែលមានស្រាប់ឱ្យបានគង់វង្ស ចាត់វិធានការទប់ស្កាត់ និងបង្ការភ្លើងឆេះព្រៃ
- រក្សា និងការពារដីទំនាបលិចទឹកសម្រាប់ដាំព្រៃលិចទឹកឡើងវិញ
- លែងទៅក្នុងធម្មជាតិវិញនូវវារីសត្វដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ នៅពេលដែលធ្វើនេសាទបាន
- ការពារសត្វព្រៃគ្រប់ប្រភេទនៅក្នុងដែននេសាទ ឬព្រៃលិចទឹក ។

**ប្រការ ៧:** ភាគី ខ មិនត្រូវធ្វើសកម្មភាពដែលបង្កឱ្យខូចដែននេសាទ ឬគ្រោះថ្នាក់ដល់ធនធានជលផលដូចខាងក្រោម :

- ចាប់នូវធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ដូចមានចែងក្នុងប្រកាសរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ដូចជាផ្សោតជាដើម ។

- លើកទំនប់ លុប រឹជីក បឹង ព្រែក ប្រឡាយ រណ្តៅ បៀវ ស្រះ ដែលពុំមានការអនុញ្ញាតពីស្ថាប័នជំនាញ
- កាប់ ឆ្ការ គាស់ រាន ឈូសឆាយព្រៃលិចទឹក ក្នុងគោលបំណងហ៊ុមព័ទ្ធយកដីជាកម្មសិទ្ធ រឺ វាតដីធ្វើស្រែចំការ ឬគោលបំណងផ្សេងៗ
- ធ្វើនេសាទ កាប់ព្រៃ ឬអុសក្នុងកន្លែងអភិរក្សជលផល ក្នុងកន្លែងនេសាទសហគមន៍
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ជាពិសេសឧបករណ៍នេសាទឆក់ត្រី និងឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ
- ប្រើប្រាស់ឧបករណ៍នេសាទខុសពីការកំណត់នៅក្នុងឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ
- ចិញ្ចឹមត្រី ឬដាំឈូក សារាយ ដែលជាពូជនាំឱ្យខូចដល់បរិស្ថានធម្មជាតិបំផ្លិតបំផ្លាញដល់ធនធានជលផល ឬបង្ករ អន្តរាយដល់ដែននេសាទ
- ធ្វើនេសាទ រឺអាជីវកម្មផ្សេងៗទៀតដែលប៉ះពាល់ ឬរំខានដល់ការលូតលាស់នៃរុក្ខជាតិទឹក
- ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទសៃមុងគ្រប់ប្រភេទ ឈិបយន្តនិងអួនអួស ទឹកសាប
- ដាំ ឬថែរក្សាជំនាំឈូកក្នុងដែននេសាទ
- ធ្វើនេសាទដោយមង ឬអួនគ្រប់ប្រភេទដែលមានក្រឡាតូចជាង ១.៥ សង្ទីម៉ែត និងធំជាង ១៥ សង្ទីម៉ែត ក្នុងដែលនេសាទទឹកសាប ។

**ប្រការ ៨:** ភាគី ២ ត្រូវចាត់វិធានការថែរក្សាការពារកន្លែងនេសាទសហគមន៍ដោយបំផុស ជុំរុញ និងលើកទឹកចិត្តដល់សមាជិកសហគមន៍នេសាទគ្រប់រូបឱ្យរាយការណ៍ទៅសមត្ថកិច្ចរដ្ឋបាលជលផលដែលនៅជិតបំផុតដើម្បីសហការទប់ស្កាត់បទល្មើស ជលផល ។

**ប្រការ ៩:** ភាគី ២ ត្រូវអនុវត្តនូវភារកិច្ចដូចខាងក្រោម :

-ប្រតិបត្តិយ៉ាងម៉ឺងម៉ាត់តាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

-ធានាអោយសមាជិកទាំងអស់ក្នុងសហគមន៍មានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផល

-សហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរដែលពាក់ព័ន្ធ ។

**ប្រការ ១០:** ប្រសិនបើភាគី ខ មិនអនុវត្តតាមប្រកាទាំងឡាយនៃកិច្ចព្រមព្រៀងនេះ ធ្វើឱ្យអន្តរាយដល់ដែននេសាទ ឬ ធនធាន ជលផលត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

**ប្រការ ១១:** កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍អាចឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយដូចមានចែងក្នុង មាត្រា ២៧ នៃអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ។

ក្នុងករណីដែលសហគមន៍នេសាទយល់ថាការបញ្ឈប់កិច្ចព្រមព្រៀងពុំមានលក្ខណៈសមស្របសហគមន៍នេសាទ អាច ធ្វើការតវ៉ាមកប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល។

**ប្រការ ១២:** កិច្ចព្រមព្រៀងនេះអាចធ្វើការកែប្រែបានតាមការឯកភាពរបស់ភាគីទាំងពីរ ស្របតាមច្បាប់និងលិខិតបទដ្ឋាននានា ពាក់ព័ន្ធនឹងសហគមន៍នេសាទ។

កិច្ចព្រមព្រៀងនេះត្រូវតម្កល់ទុកនៅស្នាក់ការសហគមន៍នេសាទ សាលាឃុំ សង្កាត់ ខណ្ឌរដ្ឋបាលជលផល សាលាខេត្ត រដ្ឋបាលជលផលថ្នាក់កណ្តាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយអាចចម្លងជូនស្ថាប័នពាក់ព័ន្ធ ដោយច្បាប់ ចម្លងត្រូវមានប្រថាប់ត្រា។

ថ្ងៃទី 24 ខែ 08 ឆ្នាំ 2012

**ភាគី ក**

**នាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់**

ហត្ថលេខា

**ភាគី ខ**

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ហត្ថលេខា

ជី គ័គ័

**សាក្សី**

មេឃុំ សៀ សួ

ហត្ថលេខា

ផា_គីមសឿន

# បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ

*ភូមិក្ដីឈ្វិត ឃុំស្រែស្ពុក ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់*

| ល.រ | ឈ្មោះសមាជិក | ភេទ | អាយុ | ភូមិ | ឃុំ | ថ្ងៃ.ខែ.ឆ្នាំចូលជាសមាជិក |
|---|---|---|---|---|---|---|
| ១ | អ៊ុក ឱម | ស | ៥៦ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២ | ឈន យ៉ក | ប | ៤៥ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ៣ | ស៊ុះ សំប៊ី | ស | ២៨ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ៤ | ចិន សល់ | ស | ២៣ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ៥ | ខូ ខេន | ស | ៥២ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ៦ | ហាយ ហ៊ត | ស | ២២ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ៧ | វ៉ក់ រី | ស | ២៤ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ៨ | មិត្ត យ៉ែន | ប | ៤៧ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ៩ | តាប់ ហុន | ស | ២៥ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១០ | រិន គឿម | ស | ២៧ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១១ | គឿន គន | ស | ២៧ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១២ | គិត ធីដា | ស | ២៧ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១៣ | យន ខេង | ស | ៣២ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១៤ | យឺន ថន | ស | ៣១ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១៥ | អិន សួយ | ស | ៣២ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១៦ | លាវ ឡាំ | ស | ៤៧ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១៧ | កង គាន | ស | ៤៦ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១៨ | យន យិន | ប | ៣៦ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ១៩ | រ៉ែន សុខ | ស | ៤២ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២០ | ចាន់ វ៉ាន | ស | ៤១ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២១ | ហាន ណារី | ស | ២៦ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២២ | រិន សេន | ស | ៣៤ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២៣ | គង់ ឈឿន | ស | ៥២ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២៤ | ហ៊ុន ប៊ុត | ស | ៤៨ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២៥ | ម៉ោញ មឿន | ស | ៤៤ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២៦ | ម៉ោង ប៉ូច | ស | ៤៧ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២៧ | ម៉ោញ ម៉ៅ | ស | ២៧ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២៨ | សុត ជន | ស | ៣៨ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ២៩ | ម៉ោញ យ៉ាត | ស | ៥៥ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |
| ៣០ | ណែវ ដឹ | ប | ៣៤ | ក្ដីឈ្វិត | ស្រែស្ពុក | ០១-០១-២០០៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣១ | ចាន់ ស្រីមុំ | ស | ២១ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៣២ | វ៉ាញ ញ៉ាន់ | ស | ៥៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៣៣ | វឿន ណារិ | ស | ៤៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៣៤ | ហ៊ន ហ៊ឹង | ស | ៤៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៣៥ | ឃន ឃិត | ស | ៥១ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៣៦ | ហ៊ន ឃន | ស | ២១ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៣៧ | វ៉ាត វ៉ាន | ស | ៤៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៣៨ | ង៉ក់ គក់ | ប | ៤៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៣៩ | ឡុង ផាន | ស | ២៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤០ | យាយ ឆយ | ស | ៥៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤១ | ខូយ ខុំ | ស | ២២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤២ | យ៉ឹង យ៉ាន្នី | ស | ២១ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤៣ | មួន គត់ | ស | ៤៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤៤ | វង្ស ឃ្មី | ស | ៣៩ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤៥ | គយ ជាវ | ស | ៥៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤៦ | ធុយ ឆេង | ស | ៤៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤៧ | ខឿន រ៉េត | ស | ២៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤៨ | វិន កុយ | ស | ៤១ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៤៩ | ដា យុត | ស | ៦៦ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥០ | គិត យឹម | ស | ៥១ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥១ | គិត កង | ស | ២៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥២ | វ៉ាត វឿន | ស | ២៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥៣ | វ៉ាត ខាន់ | ប | ៤១ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥៤ | វេ ធានី | ស | ២៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥៥ | កង ញ៉េន | ស | ៥៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥៦ | ឡាក់ ស្រីម៉ៅ | ស | ២៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥៧ | ឡាក់ ឃ្លាប | ស | ២៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥៨ | វ៉ាត ខេង | ប | ៤៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៥៩ | កោ ក | ស | ៣៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៦០ | ណាំ នី | ស | ២២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៦១ | ខាន់ សាក់ | ស | ៤៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៦២ | ឡាក់ លី | ប | ៣៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៦៣ | យ៉ឹង យ៉ុន | ប | ៣៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ៦៤ | វ៉ាត គឿម | ស | ៤៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៦៥ | ហួយ ហាយ | ប | ៤៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៦៦ | វង្ស សិត | ប | ៤៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៦៧ | ឃន ឃឿន | ប | ៤២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៦៨ | វ៉ែម ហុន | ស | ៥២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៦៩ | ណុច ម៉ឹង | ប | ៣២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧០ | ហាក់ ឃ្មី | ស | ២៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧១ | ឈាង ធូយ | ស | ៣៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧២ | វិន សិត | ស | ៣៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧៣ | ង៉ក សូត | ប | ៣៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧៤ | កាក់ សឹង | ស | ៥៦ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧៥ | វិន ខូយ | ប | ៣៩ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧៦ | ហាន ហ៊ីន | ប | ៣៩ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧៧ | អ៊ា អ៊ាន | ស | ២៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧៨ | ខឿន ខេន | | ២៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៧៩ | ឡៅ ស៊ិត | ប | ៤១ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨០ | កង ឡាំ | ស | ៥៦ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨១ | សន់ លាង | ស | ២៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨២ | វេ វ៉េត | ប | ២៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨៣ | ធឹប យ៉ាង | ស | ៥៦ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨៤ | យឹង ផល | ស | ២៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨៥ | តាប់ តន | ប | ២២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨៦ | លន់ លី | ប | ៣៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨៧ | អ៊ី ច្រឹប | ស | ២៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨៨ | ហាយ ហ៊ា | ស | ២៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៨៩ | សរ គេម | ស | ៥២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៩០ | ឈឿម ឈុន | ប | ២៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៩១ | វ៉ែន កៅនី | ស | ៣៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៩២ | លន់ គោ | ប | ២២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៩៣ | វ៉ាត អ៊ាង | ស | ២១ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៩៤ | គិត សំ | ប | ២៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៩៥ | វិន សុខ | ស | ៣៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៩៦ | ណាំ អ៊ា | ស | ៤២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ៩៧ | សាក់ ភាន | ស | ៣៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៩៨ | សាក់ ភី | ស | ២៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ៩៩ | ជួ រឿន | ប | ៤៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០០ | ពឿន ផាន | ស | ៤៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០១ | ឆាង ធុន | ស | ៤៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០២ | នៃ ខូង | ស | ៤៦ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០៣ | ហ៊ិន ចាន់ | ស | ៣២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០៤ | ប៊ិន គិត | ប | ៥៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០៥ | លាវ គីម | ស | ៥៤ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០៦ | សុង ហ៊ី | ស | ៤៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០៧ | អុន ញ៉ុន | ប | ៤៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០៨ | ឡី ជិប | ប | ៣៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១០៩ | ខូ ឌុន | ប | ៣២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១០ | ព្រិក ឡឿម | ស | ២៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១១ | ហ៊ិន ហ៊ាង | ស | ២២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១២ | ដឿន ពេញ | ប | ៣៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១៣ | ឃាន ផល់ | ស | ៣៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១៤ | ហ៊ិន ហុន | ប | ៤៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១៥ | កុយ បូរ | ស | ៤៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១៦ | ព្រិក ឌី | ស | ៣៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១៧ | ឈឿន ទីណា | ស | ២៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១៨ | តាប់ តៃ | ប | ៣៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១១៩ | សេង ណៃគី | ស | ៣៥ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២០ | សូ គាន | ស | ៥៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២១ | ថន ជា | ប | ៣៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២២ | ពឿន ខន | ស | ៥៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២៣ | សិត ហុង | ស | ២៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២៤ | ពឿន ភាន | ស | ៣៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២៥ | កែន ហ៊ី | ស | ៣៦ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២៦ | កែន គី | ស | ៣៨ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២៧ | យ៉ុម គាំង | ប | ៤៣ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២៨ | សិទ្ធិ សួ | ប | ៤២ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |
| ១២៩ | ជិវ ជឿម | ប | ៤៧ | ក្តីឈ្វិត | ស្រែស្តុក | ០១-០១-២០០៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៣០ | ហាម ចិន | ប | ៥៧ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៣១ | ថាំង តាន់ | ស | ៤៧ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៣២ | ខូយ ខឿម | ប | ៣២ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៣៣ | ស៊ន ឈុនលី | ប | ៤២ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៣៤ | ស៊ុន ប៊ុនលេង | ប | ៥៦ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៣៥ | រឿន ស្រស់ | ប | ៣១ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៣៦ | ឡាយ ជឿន | ប | ៤១ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៣៧ | តាប់ តន | ប | ៣៣ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៣៨ | ដួង លន់ | ប | ៥៨ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៣៩ | ថាប់ ម៉ោញ | ប | ៦៨ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤០ | ហាម ហុន | ប | ៤៧ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤១ | ហួយ ហាន | ប | ៦២ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤២ | ឃន ផង | ប | ៣៥ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤៣ | អ៊ិត ម៉ន | ស | ៦៨ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤៤ | យី ខែត | ប | ២៣ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤៥ | ឈាង ឈា | ប | ៣៦ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤៦ | កាក់ ខាត់ | ស | ៥២ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤៧ | ម៉ុត អាន | ស | ៦៣ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤៨ | ឃឹម ឃៀន | ប | ៣៨ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៤៩ | ចាយ ថន | ប | ៣៦ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥០ | ថន ថុន | ប | ២៧ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥១ | គិត គុណ្ណី | ប | ៣៥ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥២ | ហ៊ីង ឈឿង | ប | ៥៨ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥៣ | ហ៊ន ហ៊ាងលី | ស | ២៥ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥៤ | វ៉ាវ យៀប | ស | ៤៣ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥៥ | ខឿន ខេន | ប | ៣៨ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥៦ | សោម សារឿន | ប | ៤៥ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥៧ | ព្រឹក ឌិន | ស | ៣២ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥៨ | សូ សាំង | ប | ៥៩ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៥៩ | ឌឹម សុំ | ស | ៦២ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៦០ | ហ៊ុន ចាន់ | ប | ៤៣ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៦១ | នុយ ណម | ប | ៤៧ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៦២ | សិទ្ធ សួ | ស | ៤៣ | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៦៣ | អ៊ិត - ម៉េង | ស | 67 | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៦៤ | ម៉ុន ម៉ែស | ប | 24 | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៦៥ | ថៃ - ធឿន | ប | 31 | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៦៦ | គាប - ឌី | ប | 44 | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៦៧ | ឃាម - ខ៉ី | ប | 26 | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |
| ១៦៨ | សុវ - ភី | ប | 23 | ក្ដីឈ្វិត | ស្រែស្ដុក | ០១-០១-២០០៩ |

សមាជិកសរុបមានចំនួន...168...រូប ក្នុងនោះសមាជិកបុរសមានចំនួនសរុប...65...រូប និងសមាជិកស្ត្រីមានចំនួនសរុប...103...រូប ។

**ធ្វើនៅស្រែស្ដុក**

ថ្ងៃទី...16...ខែ...09...ឆ្នាំ...2010...

**ប្រធានសហគមន៍នេសាទភូមិក្ដីឈ្វិត**

ហត្ថលេខា

ផុក គក់

**បានឃើញ និង ពិនិត្យ**

ពិតជាមានសមាជិកតាមចំនួនដូចខាងលើមែន

**ស្រែស្ដុក ថ្ងៃទី...16...ខែ...09...ឆ្នាំ...2010**

**មេភូមិក្ដីឈ្វិត**

ហត្ថលេខា

ធឿន ណាឌិង

**បានឃើញ និង ឯកភាព**

**ស្រែស្ដុក ថ្ងៃទី...10...ខែ...10...ឆ្នាំ...2010**

**មេឃុំស្រែស្ដុក ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់**

ហត្ថលេខា

ជារ៉ា គីមសឿន

# បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទក្តីឈ្វិត

| ល.រ | ឈ្មោះ | ភេទ | អាយុ | ភូមិ | តួនាទី |
|---|---|---|---|---|---|
| ១ | ង៉ក់ គក់ | ប | ៤៩ | ក្តីឈ្វិត | ប្រធាន |
| ២ | មួន ហ៊ី | ប | ៣៦ | ក្តីឈ្វិត | អនុប្រធាន |
| ៣ | ណុច ម៉ឹង | ប | ៣៥ | ក្តីឈ្វិត | អនុប្រធានទទួលបន្ទុកលេខា |
| ៤ | វឿន សៅរិន | ប | ៤៩ | ក្តីឈ្វិត | បេឡា |
| ៥ | លាវ ឡាំ | ស | ៥០ | ក្តីឈ្វិត | សមាជិកផ្សព្វផ្សាយ |
| ៦ | យឹង យ៉ុន | ប | ៣៦ | ក្តីឈ្វិត | សមាជិកផ្សព្វផ្សាយ |
| ៧ | យន យឿង | ប | ៥០ | ក្តីឈ្វិត | ប្រធានល្បាត |
| ៨ | ឡាក់ លី | ប | ៣៧ | ក្តីឈ្វិត | សមាជិកល្បាត |
| ៩ | ង៉ក់ សួត | ប | ៤៧ | ក្តីឈ្វិត | សមាជិកល្បាត |
| ១០ | វិន ខូយ | ប | ៣៣ | ក្តីឈ្វិត | សមាជិកល្បាត |
| ១១ | យឹង ផល | ប | ៣៩ | ក្តីឈ្វិត | សមាជិកល្បាត |

ធ្វើនៅ ក្តីឈ្វិត ថ្ងៃទី 04 ខែ 08 ឆ្នាំ 2012

**ប្រធានគណៈកម្មការសហគមន៍នេសាទក្តីឈ្វិត**

ហត្ថលេខា

.........................

ង៉ក់ គក់

**បានឃើញ និង បញ្ជាក់ថា**

ឈ្មោះនៅក្នុងបញ្ជីខាងលើនេះគឺជាសមាជិកគណៈ

កម្មការសហគមន៍នេសាទក្តីឈ្វិតពិតប្រាកដមែន។

**ធ្វើនៅ ស្រែស្ពក**

**ថ្ងៃទី** 10 **ខែ** 10 **ឆ្នាំ** 2012

**មេឃុំស្រែស្ពក**

ហត្ថលេខា

.........................ចឹមសឿន

# រចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទក្ដីឈ្វិត



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៙៙៙៙

# លក្ខន្តិកៈសហគមន៍នេសាទក្តីឈ្វិត

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | :ក្តីឈ្វិត |
| ភូមិ | :ក្តីឈ្វិត |
| ឃុំ | :ស្រែស្តុក |
| ស្រុក | :កណ្តៀង |
| ខេត្ត | :ពោធិ៍សាត់ |

# ជំពូកទី ១
## គោលបំណង និងនាមករណ៍

**ប្រការ ១:** លក្ខន្តិកៈនេះមានគោលបំណង៖

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានជលផលរបស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ ។

**ប្រការ ២:** ឈ្មោះសហគមន៍នេសាទ **ក្តីឈ្វិត** ហៅកាត់ថា **ស ន ក ឈ**

អាសយដ្ឋាន : ភូមិ ក្តីឈ្វិត ឃុំស្រែស្តុក ស្រុក កណ្តៀង ខេត្តពោធិ៍សាត់ ។ សហគមន៍នេសាទនេះមានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង ភូមិក្តីឈ្វិត ឃុំស្រែស្តុក ស្រុកណ្តៀង ខេត្តពោធិ៍សាត់ ។

**មានកម្មវត្ថុ :** ដើម្បីចូលរួមចំនែកលើកស្ទួយជីវភាពប្រជាពលរដ្ឋតាមរយៈការថែរក្សាការពារ ប្រើប្រាស់ និងអភិរក្ស អភិវឌ្ឍន៏ធនធានជលផលអោយបានគង់វង្សទៅអនាគត ។

# ជំពូកទី ២
## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភាតព្វកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣:** ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងចង់ចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំ ចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង ។

**ប្រការ ៤:** សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើមានសិទ្ធិ៖

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោតនិងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទស្របតាមលក្ខន្តិកៈនិងបទ

បញ្ហាផ្ទៃក្នុងសហគមន៍នេសាទនេះ

- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើ មានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅរដ្ឋបាល ជលផលមានសមត្ថកិច្ច ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ។
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍។

សមាជិកសហគមន៍នេសាទត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួននិងរួមគ្នាចំពោះកំហុសដែលខ្លួនបាន ប្រព្រឹត្តក្នុងពេលបំពេញភារកិច្ចដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់ (១/១០) ឡើងទៅអាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិក សហគមន៍នេសាទដែលបានស្នើសុំខាងលើនេះអាចចាត់តំណាងចំនួនបី(៣) នាក់ចូលរួមប្រជុំដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹងចំណុចដែលបានស្នើឡើងនោះ។

**ប្រការ ៥:** សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម៖

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និង លិខិតបទដ្ឋានផ្សេងៗទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទ សហគមន៍
- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ

- បង់ប្រាក់សមាជិកភាពចំនួន ៥០០រៀល តាមការសម្រេចរបស់មហាសន្និបាត នៅពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន ៥០០រៀល តាមការសម្រេចរបស់មហាសន្និបាត
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍។

## ជំពូកទី ៣

## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

**ប្រការ ៦:** សមាជិកសហគមន៍នេសាទ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ៖

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ ៧:** សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ការមិនបង់ភាគទានចំនួន ៣ លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ។

## ជំពូកទី ៤

## របៀបរបបកាន់បញ្ជី និង ឯកសារនានា

**ប្រការ ៨:** ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី៖

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការក្រៅរដ្ឋាភិបាល
- ចំណូលស្របច្បាប់ផ្សេងៗទៀត ។

**ប្រការ ៩:** រាល់ការចំណាយថវិកា សហគមន៍ត្រូវអនុវត្តដូចតទៅ៖

- ការចំណាយពី ១០០រៀល ដល់ ១០០០០រៀល ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ ។
- ការចំណាយពី ១០១០០រៀល ដល់ ១៥០.០០០រៀល ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ ។
- ការចំណាយពី ១៥០.០០០រៀលឡើងទៅ ត្រូវសម្រេចដោយមហាសន្និបាតសម្រេចពីសមាជិកសហគមន៍នេសាទ ។

**ប្រការ ១០:** សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី:

- ចំណូល ចំណាយថវិកា
- សារពើភ័ណ្ឌ
- សមាជិកសហគមន៍នេសាទ
- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ
- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ
- ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

**ប្រការ ១១:** ការគ្រប់គ្រង និងប្រើប្រាស់ថវិកា៖

- ការគ្រប់គ្រងថវិកា ត្រូវអនុវត្តតាមប្រព័ន្ធការងារគណនេយ្យ
- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ
- រាល់ថវិកាចំណាយ ត្រូវមានវិក័យបត្រ និងបញ្ជីត្រឹមត្រូវ
- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍសហគមន៍នេសាទ ។

## ជំពូកទី ៥

## គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១២៖** សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក ។ ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំនិងគ្រប់គ្រងសហគមន៍នេសាទទាំងមូល ។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន ។គណៈកម្មការសហគមន៍ត្រូវពិភាក្សាបែងចែកភារកិច្ចតាមការជាក់ស្តែង ។

**ប្រការ ១៣៖** គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ (៥) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតឱ្យចូលកាន់តំណែង ជំនួស ។ ក្នុងករណីដែលសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាពក្នុង ការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាត វិសាមញ្ញដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី ។

**ប្រការ ១៤៖** ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាមួយអវត្តមាន ដោយគ្មានមូលហេតុ រយៈពេលប្រាំមួយ (៦) ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស ។

## ជំពូកទី ៦
## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥៖** គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ ។

**ប្រការ ១៦៖** ប្រធានគណៈកម្មការសហគមន៍នេសាទ ជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមានអនុប្រធានដែលត្រូវបានប្រគល់សិទ្ធិត្រូវធ្វើជាប្រធានអង្គប្រជុំ ។ រាល់ ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់ ។ ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ មានរបៀប រៀបរយ និងគ្មានការរំខាន ។ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យ ខូចសណ្តាប់ធ្នាប់អង្គប្រជុំ ។

**ប្រការ ១៧៖** ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈ កម្មការសហគមន៍នេសាទទាំងអស់៖

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានការខុសឆ្គង
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មដល់សមាជិកសហគមន៍នេសាទ ឬ សមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់ ។

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាមប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន ។សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបិទ ផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំ សង្កាត់ ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរបន្ទាប់ពីការ ប្រជុំ។

## ជំពូកទី ៧

## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨៖** មហាសន្និបាតសហគមន៍នេសាទជាអង្គការកំពូល សម្រាប់ធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងនាមសហគមន៍នេសាទ ។មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទត្រូវប្រារព្ធធ្វើឡើង បន្ទាប់ពី ក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត ។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ ដោយមានការ ជួយសម្របសម្រួលពីរដ្ឋបាលជលផលមានសមត្ថកិច្ច តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពី សមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទអនុម័តនូវសេចក្តីសម្រេចនិងកិច្ចការសំខាន់ដូចខាង ក្រោម៖

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ។

**ប្រការ ១៩:** មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ។ ក្នុងករណីចាំបាច់ សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំ ពីសមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) យ៉ាងតិច។

**ប្រការ ២០:** គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផលមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុង មហាសន្និបាតសហគមន៍នេសាទ។

**ប្រការ ២១:** លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម៖

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈនិងបិទប្រកាសនៅសាលាឃុំសង្កាត់ និងទីស្នាក់ការ សហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើងដប់ (១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី (៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ។
- មហាសន្និបាតសាមញ្ញឬវិសាមញ្ញអាចប្រជុំពិភាក្សាអនុម័តនិងសម្រេចបានលុះត្រាតែមានវត្តមានលើស ពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ។
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន
- លេខាកត់ត្រា និងប្រធានអង្គប្រជុំត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាត ត្រូវយកសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមានវត្តមាន។

**ប្រការ ២២:** មហាសន្និបាតអនុម័ត៖

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៩ កថាខណ្ឌទី ៤ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ ។

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣:** ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយ មហា សន្និបាត ។

**ប្រការ ២៤:** កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទគឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត ។គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាពពីបី(៣)ទៅប្រាំ(៥)នាក់ដែលមានប្រធាន អនុប្រធាន និងសមាជិកតាមការកំណត់ជាក់ស្តែងនៃមហាសន្និបាតនិងត្រូវមាន លក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ។ គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្ត បង្ហាញពីភាពស្មោះត្រង់ ។

**ប្រការ ២៥:** គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ច ដូចខាងក្រោម៖

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត
- បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីប្រកាសជូនមហាសន្និបាត
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផល បោះឆ្នោតចប់ជាស្ថាពរ ។

**ប្រការ ២៦:** បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការ

សហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការសហគមន៍នេសាទតាមលំដាប់លំដោយ ។ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នាត្រូវជ្រើសរើសស្ត្រី ឬបោះ ឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្ដាលនៃចំនួនសមាជិកសហគមន៍នេសាទដែល ចូលរួម ។

## ជំពូកទី ៩
## លក្ខខណ្ឌនៃការរំលាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧:** ការរំលាយសហគមន៍នេសាទត្រូវផ្អែកតាម៖

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀង កន្លែងនេសាទសហគមន៍
- សេចក្ដីសម្រេចមហាសន្និបាតដោយមូលហេតុសហគមន៍គ្មានសកម្មភាពក្នុងរយៈពេល ២ ឆ្នាំ ជាប់ៗគ្នា
- ការឯកភាពផ្ទៃក្នុងរបស់សមាជិកសហគមន៍នេសាទ
- ក្រោយពីរំលាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវអនុម័តតាមមហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៨:** ក្នុងករណីមានការតវ៉ាចោទប្រកាន់ថាដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតីអ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាមនៅមុនពេល ប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

**ប្រការ ២៩:** វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម៖

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះ ទៅសមត្ថកិច្ចជំនាញដោះស្រាយទៅតាមឋានានុក្រម ។

**ប្រការ ៣០:** សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួល

ទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទឬមហាសន្និបាតសហគមន៍នេសាទទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន។

## ជំពូកទី ១០

## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១:** ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត។

ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែមុនបើក មហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះអាចកែប្រែបានលុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្តាល នៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៣២:** លក្ខន្តិកៈសហគមន៍នេសាទនេះ បានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃទី.......ខែ......ឆ្នាំ២០.......និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់គណៈកម្មការសហគមន៍នេសាទ ។

ធ្វើនៅ...ស្ទឹងត្រែង...ថ្ងៃទី..០៤..ខែ..០៧.....ឆ្នាំ..2012

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ហត្ថលេខា

[signature]

.............ម៉ក់ គក់.............

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៙៛៛

# បទបញ្ជាផ្ទៃក្នុងសហាគមន៍នេសាទក្ដីឈ្វិត

## បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អសហគមន៍នេសាទ ក្ដីឈ្វិត សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម៖

**ប្រការ ១ :** គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ដាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ។

**ប្រការ ២:** គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ៖

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀតត្រូវសង ឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្ដែង តាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ។ ក្នុងករណីមិនព្រមសងត្រូវដាក់ជូនមហា សន្និបាតសម្រេច។
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត។ ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបាន ត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន។

**ប្រការ ៣:** សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបាន មកចូលរួមប្រជុំចំនួន៣ដងជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍ នេសាទ។

ករណីនៅតែមិនរាងចាលគណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព។

**ប្រការ ៤:** សិទ្ធិដាក់ទណ្ឌកម្ម៖

**ក-គណៈកម្មការសហគមន៍នេសាទ**

- អប់រំណែនាំលើកទី១ លើកទី២ និងលើកទី៣

- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ
- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅរដ្ឋបាលជលផលមានសមត្ថកិច្ច ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍ ។

**ខ-មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៨ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន ។

**ប្រការ ៥:** សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទអំពីសំភារៈឧបករណ៍ នេសាទដែលគ្រួសារនីមួយៗប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ។

**ប្រការ ៦:** សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារនៅក្នុងរដូវបើកនេសាទដូចមានចែងខាងក្រោម:

- មងប្រវែងមិនលើសពី៥០០ ម៉ែត្រ
- សន្ទូចរបង ១០០០ផ្លែ
- លប ៥០លប
- លាន់ ១០០លាន់
- ជូ ៥០ជូ
- និងសំភារៈផ្សេងៗទៀត ដូចជា ទ្រូ ជុក អរងុត សំណាញ់ ជាដើម ។

***សំគាល់*** *:ការប្រើប្រាស់ឧបករណ៍នេសាទនឹងមានការកែប្រែបន្ទាប់ពីមានការសម្រេចសេចក្តី ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ស្តីពីការប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ។*

**ប្រការ ៧៖** សមាជិកសហគមន៍នេសាទដែល៖

- ប្រព្រឹត្តផ្ទុយ ឬរារាំងមិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈ ត្រូវព្យួរ សមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត
- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផលត្រូវព្រមាន ដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការរានព្រៃលិចទឹក ព្រៃកោងកាង ឬបំផ្លាញផ្កាថ្ម ឬស្មៅសមុទ្រ ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមត្ថកិច្ចដើម្បីដោះស្រាយតាមច្បាប់ ។

**ប្រការ៨៖** ចំពោះអ្នកប្រើប្រាស់ធនធានជលផល ដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័តិមានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យានិងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងនិងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាម ប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំ ណែនាំ ។

**ប្រការ ៩៖** បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅថ្ងៃទី.....ខែ.....ឆ្នាំ២០......និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយគណៈកម្មការសហគមន៍នេសាទ ។

ធ្វើនៅ...ក្ដីឈ្មិត...ថ្ងៃទី...6...ខែ...7...ឆ្នាំ...2012

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ហត្ថលេខា

..........................................

# សេចក្តីថ្លែងការណ៍

យើងខ្ញុំជាគណៈកម្មការសហគមន៍នេសាទ "ក្តីឈ្មិត " ដែលស្ថិតក្នុងឃុំស្រែស្តុក ស្រុកកណ្តៀង ។ សហគមន៍នេសាទនេះបានចាប់ផ្តើមរៀបចំបង្កើតឡើងតាំងពីឆ្នាំ ២០០៧ មកម្លេះ និងបន្តដំណើការនៃការបង្កើតសហគមន៍នេសាទនេះរហូតដល់ឆ្នាំ២០១២ ក្រោមការជួយគាំទ្របច្ចេកទេសដោយខណ្ឌរដ្ឋបាលជលផលក្នុងកិច្ចសហការជាមួយអង្គការស្តារកម្ពុជា។

យើងខ្ញុំសូមជម្រាបជូនលោកនាយខណ្ឌរដ្ឋបាលជលផលអោយបានជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេសាទនេះ គឺបានកើតឡើងបន្ទាប់ពីមានភាពអានាធិបតេយ្យនៃការនេសាទខុសច្បាប់ និងមានទំនាស់ដែននេសាទ បានធ្វើអោយប្រជាជនក្នុងភូមិក្តីឈ្មិតក្នុងឃុំស្រែស្តុកទាំងមូលបានឯកភាពគ្នារៀបចំសំណើរ សុំបង្កើតសហគមន៍នេសាទនេះឡើងនិងស្របទៅតាមគោលនយោបាយកំណែទំរង់វិស័យជលផលរបស់រាជរដ្ឋាភិបាល នៅឆ្នាំ២០០០។ សំណើរសុំបង្កើតសហគមន៍នេសាទនេះ គឺក្នុងគោលបំណងដើម្បីការពារ គ្រប់គ្រង ថែរក្សាអភិរក្ស ប្រើប្រាស់ និងអភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយចីរភាព ដើម្បីចូលរួមកាត់បន្ថយភាគក្រីក្រ ក្នុងសហគមន៍មូលដ្ឋាន។

ចាប់តាំងពីចាប់ផ្តើមបង្កើតសហគមន៍នេសាទ រហូតមកដល់សព្វថ្ងៃនេះ សហគមន៍នេសាទយើងខ្ញុំបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើនដូចជា ការផ្សព្វផ្សាយដើម្បីបង្កើនការចូលរួមពីសមាជិកសហគមន៍ក្នុងការគ្រប់គ្រងធនធានជលផល ការបង្កើតគណៈកម្មការសហគមន៍នេសាទ ការរៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍ ការរៀបចំនិងអនុម័តទៅលើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង ម្យ៉ាងវិញទៀត បានចូលរួមក្នុងការកំណត់ផែនទីដែននេសាទនិងដែនអភិរក្សរបស់សហគមន៍ មិនតែប៉ុណ្ណោះយើងខ្ញុំបានរៀបចំកាលវិភាគច្បាស់លាស់ក្នុងការចុះល្បាត ការបង្ក្រាបបទល្មើសនេសាទការទប់ស្កាត់ការពង្រីកដីកសិកម្មតាមមាត់បឹងធម្មជាតិ និងរៀបចំផែនការចុះប្រមូលវិភាគទានពីសមាជិកសហគមន៍នេសាទជាដើម។ តាមរយៈសកម្មភាពដែលបានអនុវត្ត យើងខ្ញុំបានរៀបចំរួចរាល់នូវឯកសារសំខាន់ៗមួយចំនួនរបស់សហគមន៍នេសាទដូចដែលមានចែងក្នុងមាត្រាទី៧ ក្នុងជំពូកទី២ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទដែមរួមមាន

- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- បញ្ជីឈ្មោះគណៈកម្មការសហគមន៍
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- ផែនទីកន្លែងនេសាទសហគមន៍ និង
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

ដោយផ្អែកលើសមិទ្ធិផលដូចដែលបានរៀបរាប់ខាងលើ និងការសម្រេចមហាសន្និបាតដែលបានប្រារព្ធនៅថ្ងៃទី ២៤ខែសីហា ឆ្នាំ២០១២ យើងខ្ញុំគណៈកម្មការតំណាង

អោយសហគមន៍នេសាទក្តីឈ្វិតសូមគោរពជូនលោកនាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់នូវកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ដោយមានភ្ជាប់ជាមួយនូវបញ្ជីឈ្មោះសមាជិកសមាជិកសហគមន៍នេសាទ បញ្ជីឈ្មោះគណៈកម្មការសហគមន៍ លក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងសហគមន៍នេសាទ និងផែនទីកន្លែងនេសាទសហគមន៍ដើម្បីពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទក្តីឈ្វិត សូមធ្វើការប្តេជ្ញាចិត្តថា នឹងប្រឹងប្រែងអោយអស់ពីលទ្ធិភាពក្នុងការគ្រប់គ្រង ថែរក្សាសហគមន៍នេសាទដោយគោរពទៅតាមលក្ខន្តិកៈនិងបទបញ្ញាផ្ទៃក្នុងសហគមន៍នេសាទ និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងច្បាប់លិខិតបទដ្ឋាននានាដែលទាក់ទងទៅនឹងវិស័យជលផល។

ក្នុងករណីដែលយើងខ្ញុំបានប្រព្រឹត្តអ្វីខុសពីកិច្ចព្រមព្រៀងខាងលើ យើងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោកនាយខណ្ឌរដ្ឋបាលជលផលមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

ធ្វើនៅក្តីឈ្វិត ថ្ងៃទី15....ខែ..ធ្នូ......ឆ្នាំ២០១២

ប្រធានគណៈកម្មការសហគមន៍នេសាទ

ង៉ក់ គត់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រធានគណៈកម្មការសហគមន៍ក្តីឈ្វិត

គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់

កម្មវត្ថុ សំណើចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ក្តីឈ្វិត
យោង .អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៧
. សេចក្តីសម្រេចរបស់មហាសន្និបាតចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ក្តីឈ្វិត នៅថ្ងៃទី២៤ខែសីហា ឆ្នាំ២០១២
លិខិតភ្ជាប់ កម្មវិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ក្តីឈ្វិត

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកនាយខណ្ឌរដ្ឋបាលជលផល មេត្តាជ្រាបថា សហគមន៍នេសាទក្តីឈ្វិតបានចាប់ផ្តើមបង្កើតឡើងតាំងពីឆ្នាំ២០០៧មកម្លេះនិងមកទល់នឹងឆ្នាំ២០១២នេះ ក្រោមការជួយឧបត្ថម្ភផ្នែកបច្ចេកទេស ពីខណ្ឌរដ្ឋបាលជលផល និងការគាំទ្ររបស់អង្គការស្តារកម្ពុជា។ សហគមន៍ក្តីឈ្វិតមានទីតាំងស្ថិតនៅក្នុងភូមិក្តីឈ្វិត ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ដែលមានផ្ទៃដីទំហំ ហិចតា ដឹកនាំដោយគណៈកម្មការសហគមន៍នេសាទចំនួន ១១នាក់ក្នុងនោះមានស្ត្រីចំនួន២នាក់មានសមាជិកសរុប ១៦៨គ្រួសារ។ បន្ទាប់ពីបានបង្កើតរួចសហគមន៍ក្តីឈ្វិតបានដំណើរការការងារយ៉ាងស្រាក់សស្រាំ ដោយមានការចូលរួមឧត្ថម្ភគាំទ្រពីអង្គការស្តារកម្ពុជា និងផ្នែកបច្ចេកទេសពីខណ្ឌរដ្ឋបាលជលផល ស្ថាប័នជំនាញដែលពាក់ពន្ធ័ និងអាជ្ញាធរមូលដ្ឋានក្រុមប្រឹក្សាឃុំ។ ព្រមជាមួយគ្នានោះដែរ គណៈកម្មការសហគមន៍នេសាទបានរៀបចំ បញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទី និងកិចព្រមព្រៀងកន្លែងនេសាទសហគមន៍រួចជាស្រេច ព្រមទាំងបានរៀបចំពិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នៅឃុំស្រែស្តុក នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១២ ដោយមានការចូលរួមពីលោកនាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់និងសមាជិក លោកអភិបាលស្រុក ប្រធានក្រុមប្រឹក្សាឃុំស្រែស្តុក និងមានការចូលរួមពីសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ពន្ធ័ និងក្រុមប្រឹក្សាឃុំជាសាក្សី។

សូមភ្ជាប់ជូននូវ
១. កិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ
២.ផែនទីកន្លែនេសាទសហគមន៍
៣.បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ

៤.លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ

៥.សេចក្តីថ្លែងនៃការបង្កើតសហគមន៍នេសាទ

អាស្រ័យហេតុនេះសូមលោកនាយខណ្ឌរដ្ឋបាលជលផល មេត្តាពិនិត្យ និងសំរេចដោយក្តីអនុគ្រោះ។

សូមលោកទទួលយកនូវការគោរពអំពីយើងខ្ញុំ។

ធ្វើនៅក្តីឈ្វិត ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២

គណៈកម្មការសហគមន៍នេសាទក្តីឈ្វិត

ហត្ថលេខា

# កំណត់ហេតុ
# ស្តីពីពិធីកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទ
## នៃសហគមន៍នេសាទក្តីឈ្វិត ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់

## ១. សេចក្តីផ្តើម

ពិធីចុះកិច្ចព្រមព្រៀងកន្លែងសហគមន៍នេសាទគឺជាជំហ៊ានទី៩ក្នុងចំណោមជំហ៊ានទាំង១០នៃដំណើរការការបង្កើតសហគមន៍នេសាទ។ ពិធីចុះកិច្ចព្រមព្រៀងគឺជាពិធីមួយដែលជាសញ្ញាយល់ព្រមប្រគល់តំបន់មួយទៅអោយសហគមន៍នេសាទថែរក្សាដោយស្របច្បាប់ និងមានការទទួលស្គាល់ត្រឹមត្រូវពីសំណាក់អាជ្ញាធរមូលដ្ឋាន ស្រុក ជលផលខេត្តនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងក្រសួងធនធានទឹក។

ក្តីឈ្វិតគឺសហគមន៍នេសាទមួយ ដែលជាគោលដៅរបស់អង្គការស្តាកម្ពុជាហើយបានចំណាយពេលវេលាប្រមាណជាជាង២ឆ្នាំដោយរាប់តាំងពីឆ្នាំ២០១០មកដើម្បីឈានដល់ការប្រារព្ធពិធីចុះកិច្ចព្រមព្រៀងនេះឡើង។គួរបញ្ជាក់ផងដែរថាអង្គការដៃគូរខេត្តVAPSDចាប់ផ្តើមសកម្មភាពនេះដើម្បីឆ្លើយតបទៅតាមតំរូវការរបស់សហគមន៍តាំងពីឆ្នាំ២០១០មកម្លេះ បន្ទាប់មកអង្គការស្តារកម្ពុជាបានចុះផ្ទាល់បន្តលើការងារចាស់ចាប់ពីពាក់កណ្តាលឆ្នាំ២០១២មក។

គោលបំណងជារួមរបស់សហគមន៍ក្តីឈ្វិតក្នុងការបង្កើតសហគមន៍នេសាទនេះ គឺដើម្បីថែរក្សាធនធានធម្មជាតិអោយមាននិរន្តរភាពនិងការអភិវឌ្ឍន៍ដោយមានការចូលរួមពីសហគមន៍ប្រជាពលរដ្ឋនៅក្នុងភូមិក្តីឈ្វិតទាំងអស់។

ពិធីចុះកិច្ចព្រមព្រៀងនេះបានរៀបចំឡើងនៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០១២។ ទីតាំងនៅសាលាឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់។ ពិធីនេះមានអ្នកចូលរួមសរុប៩១នាក់(ស្ត្រី ៧នាក់) ព្រមទាំងបុគ្គលិកអង្គការស្តារកម្ពុជា និងម្ចាស់ជំនួយ ។ ម្យ៉ាងវិញទៀតមានការចូលរួមយកពត៌មានពីសំណាក់ វិទ្យុស៊ីសេរី ទូរទស្សន៍អាស៊ីអាគ្នេយ៍ និងទូរទស្សន៍CNC ផងដែរ។

## ២. លទ្ធផល

ពិធីចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ក្តីឈ្វិតបានប្រារព្ធឡើងនៅវេលាម៉ោង៨:០០រហូតដល់ម៉ោង១០:៤៥នាទីដោយមានការចូលរួមបើកកម្មវិធីដោយលោកអភិបាលរងស្រុកនិងការជួយសម្របសម្រួលផ្នែកបច្ចេកទេស និងពន្យល់ពីច្បាប់នានាស្តីពីជលផលដោយមន្ត្រីជំនាញជលផលខេត្ត។

លោកអភិបាលរងស្រុកបានថ្លែងអំណរគុណដល់អង្គការស្តារកម្ពុជា និងមន្ត្រីជំនាញជលផលនូវការខិតខំប្រឹប្រែងសហការក្នុងការរៀបចំសកម្មភាពបង្កើតសហគមន៍នេសាទក្តីឈ្វិតនេះឡើង ហើយលោកក៏មានមតិផ្តាំផ្ញើរដល់សមាជិកសហគមន៍ទាំងអស់អោយខិតខំយកចិត្តទុកដាក់ថែរក្សា ការពារ និងត្រូវប្រុងប្រយត្ន័ខ្ពស់ក្នុងការដកហូតយកផលត្រីក្នុងគោលបំណងដើម្បីថែរក្សាធនធានជលផលអោយចីរភាព។

បន្ទាប់មកប្រធានសហគមន៍បានឡើងថ្លែងពីប្រវត្តិរបស់សហគមន៍និងដំណើរការសកម្មភាពមួយចំនួនរបស់សហគមន៍ដែលបានធ្វើកន្លងមក។

ទន្ទឹមនឹងពិធីនេះដែរ មន្ត្រីជំនាញជលផលបានធ្វើការបង្ហាញដល់សហគមន៍នូវផែនទីដែននេសាទ និងតំបន់អភិរក្សរបស់សហគមន៍និងបាននែនាំដល់សហគមន៍អោយយកចិត្តទុកដាក់ខ្ពស់លើការថែរក្សាការពារធនធានជលផលច្បាប់ជលផល និងតំរូវអោយមានការរៀបចំជាឯកសាររបស់សហគមន៍នៅគ្រប់សកម្មភាពដែលបានធ្វើជាពិសេសសកម្មភាពប្រជុំនានាការចុះល្បាត និងការចាប់បានជនល្មើសជាដើម។

នៅចុងបញ្ចប់នៃកម្មវិធីមានការចុះហត្ថលេខាព្រមព្រៀងលើមាត្រាទាំង១២ នៃការចុះកិច្ចព្រមព្រៀងរបស់ប្រធានសហគមន៍ ប្រធានឃុំ និងប្រធានភូមិ ។ចំណែកផែនទីដែននេសាទនឹងត្រូវបិតផ្សព្វផ្សាយដល់សហគមន៍រយៈពេល៣០ថ្ងៃក្រោយពិធី ដើម្បីមានការតវ៉ាឬកែសម្រួលផ្សេងៗមុននឹងដាក់ជូនដល់ ស្រុក ជលផលខេត្ត និងក្រសួងដើម្បីចុះហត្ថលេខាយល់ព្រមជាសគល។

ពិធីចុះកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ដោយភាពស្និតស្នាល និងទទួលបានលទ្ធផលជាផ្លែផ្កានៃដំណើរការបង្កើតសហគមន៍នេសាទក្តីឈ្វិតនេះ។

ថ្ងៃសុក្រ ទី៣១ ខែសីហា ឆ្នាំ២០១២

អ្នកធ្វើកំណត់ហេតុ

អ៊ូ ឧស្សាហ៍

មន្ត្រីគម្រោងគ្រប់គ្រងធនធានធម្មជាតិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# **កំណត់ហេតុ**

ស្តីពីលទ្ធផលមហាសន្និបាតបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទក្តីឈ្វិត

ឆ្នាំពីរពាន់ដប់ពីរ ខែ ឧសភា ថ្ងៃទី២៧ វេលាម៉ោងប្រាំបួន នៅវត្តក្តីឧត្តមនៃភូមិក្តីឈ្វិត ឃុំស្រែស្តុក បានរៀបចំមហាសន្និបាតបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទក្តីឈ្វិត

ដែលមានសមាសភាពចូលរួមដូចខាងក្រោមៈ

- លោក សុខ លីមុត អភិបាលស្រុកកណ្តៀង
- លោកស្រី ជេត ចរិយា នាយកប្រតិបត្តនៃអង្គការស្តារកម្ពុជា
- លោក ឆាយ មន នាយរងខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់
- លោក សេង សុងលី មន្ត្រីខណ្ឌរដ្ឋបាលជលផល(អ្នកសម្របសម្រួល)
- លោក នាង ង៉ែត មន្ត្រីខណ្ឌរដ្ឋបាលជលផល(អ្នកសម្របសម្រួល)
- លោក យឹម ទៀង ខណ្ឌរដ្ឋបាលជលផល(អ្នកសម្របសម្រួល)
- លោក ជា គឹមសឿន ប្រធានក្រុមប្រឹក្សាឃុំស្រែស្តុក
- ក្រុមស្ថានីកសហគមន៍នេសាទ
- គណៈកម្មការរៀបចំការបោះឆ្នោត
- មេភូមិ និងប្រជាពលរដ្ឋសមាជិកសហគមន៍នេសាទ

ក្រោយមហាសន្និបាត គណៈកម្មការរៀបចំការបោះឆ្នោតបានប្រកាសលទ្ធផលគណៈកម្មការសហគមន៍នេសាទក្តីឈ្វិតដោយមានការទទួលស្គាល់ពីប្រធានក្រុមប្រឹក្សាឃុំស្រែស្តុកដូចមានឈ្មោះខាងក្រោម

| ល.រ | ឈ្មោះ | ភេទ | ចំនួនសំលេង | តួនាទីក្នុងសហគមន៍ |
|---|---|---|---|---|
| ១ | ង៉ក់ គក់ | ប្រុស | ៣១ សំលេង | ប្រធានសហគមន៍ |
| ២ | មួន ហ៊ី | ប្រុស | ១៨ សំលេង | អនុប្រធានសហគមន៍ |
| ៣ | ណុច ម៉ឹង | ប្រុស | ១៣ សំលេង | លេខា |
| ៤ | វឿន សៅរិន | ស្រី | ១៣ សំលេង | បេឡា |
| ៥ | យន យឿង | ប្រុស | ២ សំលេង | ប្រធានល្បាត |

| | | | | |
|---|---|---|---|---|
| ៦ | ឡាក់ លី | ប្រុស | ២ សំលេង | សមាជិកល្បាត |
| ៧ | ង៉ក់ សួត | ប្រុស | ១ សំលេង | សមាជិកល្បាត |
| ៨ | រិន ខូយ | ប្រុស | ២ សំលេង | សមាជិកល្បាត |
| ៩ | យឹង ផល | ប្រុស | ២ សំលេង | សមាជិកល្បាត |
| ១០ | យឹង យ៉ុន | ប្រុស | ៣ សំលេង | ផ្សព្វផ្សាយ |
| ១១ | លាវ ឡាំ | ស្រី | ១ សំលេង | សមាជិកផ្សព្វផ្សាយ |

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់មួយថ្ងៃត្រង់ថ្ងៃខែឆ្នាំដដែលប្រកបដោយបរិយាកាសរីករាយនិងសហការណ៍។

បានឃើញនិងឯកភាព
មេឃុំស្រែស្អក
ជា គឹមសឿន

ប្រធានគណៈកម្មការ
រៀបចំការបោះឆ្នោត
ប៊ិន គិត

អ្នកកត់ត្រា
បុគ្គលិកអង្គការស្តាកម្ពុជា
អ៊ូ ឧស្សាហ៍

# កំណត់ហេតុ
# ស្តីពីមហាសន្និបាតបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ និងការពិភាក្សាអនុម័តលើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង
## នៃសហគមន៍ក្តីឈ្វិត

### ១ ពត៌មានទូរទៅ

| | |
|---|---|
| *ទីកន្លែងប្រជុំ* | វត្តរតនៈក្តីឧត្តម ភូមិក្តីឈ្វិត ឃុំស្រែស្តុក ស្រុកកណ្តៀង |
| *កាលបរិច្ឆេទ* | ថ្ងៃសុក្រទី២៧ខែឧសភា ឆ្នាំ២០១២(៧:៣០ដល់១១:៣០ព្រឹក) |
| *សមាសភាពចូលរួម* | ចំនួនសរុប១១០រូប(ស្ត្រី៥៨រូប) |

### ២. គោលបំណង

- ដើម្បីធ្វើការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទស្របច្បាប់
- ដើម្បីផ្លងមតិលើលក្ខន្តិកៈ និងបទបញ្ញាផ្ទៃក្នុងនៃសហគមន៍នេសាទ
- បង្ហាញនូវផែនទីតំបន់អភិរក្សនៃសហគមន៍នេសាទ

### ៣. សមាសភាពចូលរួម

| | |
|---|---|
| លោក សុខ លីមុត | អភិបាលស្រុកកណ្តៀង |
| លោកស្រី ជេត ចរិយា | នាយកប្រតិបត្តិនៃអង្គការស្តារកម្ពុជា |
| លោក ឆាយ មន | នាយរងខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់ |
| លោក សេង សុងលី | មន្ត្រីខណ្ឌរដ្ឋបាលជលផល(អ្នកសម្របសម្រួល) |
| លោក នាង ង៉ែត | មន្ត្រីខណ្ឌរដ្ឋបាលជលផល(អ្នកសម្របសម្រួល) |
| លោក យឹម ទៀត | ខណ្ឌរដ្ឋបាលជលផល(អ្នកសម្របសម្រួល) |
| លោក ជា គឹមសឿន | ប្រធានក្រុមប្រឹក្សាឃុំស្រែស្តុក |

ប្រជាពលរដ្ឋដែលជាសមាជិកសហគមន៍នេសាទក្តីឈ្វិត

### ៣. អត្ថន័យទាំងមូលនៃកិច្ចប្រជុំ

ជាកិច្ចចាប់ផ្តើមនៃកម្មវិធីលោក សឿន សារ៉េត អ្នកសប្រមសម្រួល កម្មវិធីអង្គប្រជុំទាំងមូលបានមានមតិស្វាគមន៍ដល់អង្គប្រជុំនិងបង្ហាញពីគោលបំណងព្រមទាំងសមាសភាពនៃការអញ្ជើញចូលរួមពីសំណាក់អាជ្ញាធរស្រុកឃុំនៃការប្រជុំថ្នាក់ឃុំក្នុងថ្ងៃនេះ។

សមាសភាពចូលរួមជាគណៈអធិបតិយនិងភ្ញៀវកិត្តិយសមាន

នាយកប្រតិបត្តអង្គការស្តារកម្ពុជា

ជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំលោកស្រីជេត ចរិយានាយកប្រតិបត្តនៃអង្គការស្តារកម្ពុជាបានសំដែងនូវចំណាប់អារម្មណ៍នៃកម្មវិធីប្រជុំ និងស្វាគមន៍ចំពោះសមាជិកនៃអង្គប្រជុំទាំងមូល។ លោកស្រីបានបង្ហាញនូវសារៈសំខាន់នៃធនធានជលផលនិងសារៈសំខាន់នៃការបង្កើតសហគមន៍នេសាទផងដែរ។

លោក អភិបាលស្រុក

ជាបឋមលោកអភិបាលស្រុកបានសំដែងនូវការចំណាប់អារម្មណ៍ចំពោះអង្គប្រជុំនាថ្ងៃនេះព្រមទាំងបានលើកឡើងនូវសារៈសំខាន់នៃវិស័យជលផលហើយវាក៏ជាវិស័យមួយរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់និងអោយតំលៃដល់សារៈសំខាន់ចំពោះសេដ្ឋកិច្ចជាតិនិងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជាពិសេសប្រជាពលរដ្ឋដែលនៅតាមជនបទនិងតាមដែននេសាទនានា។ ឆ្លើយតបទៅនឹងទំហំនៃសារៈសំខាន់របស់វិស័យជលផលរដ្ឋាភិបាលកម្ពុជាបានរៀបចំយុទ្ធសាស្រ្តកំណែទម្រង់ លើវិស័យជលផលដោយកាត់បន្ថយនិងលុបឡូត៍នេសាទទូទាំងប្រទេសក្នុងនោះមានខេត្តពោធិ៍សាត់ផងដែរ។ គោលនយោបាយនេះគឺជាការផ្ទេរសិទ្ធអំណាចដល់ប្រជាពលរដ្ឋមូលដ្ឋានដើម្បីធ្វើជាម្ចាស់លើធនធានរបស់ខ្លួនដើម្បីធានាបាននិរន្តរភាពនៃធនធានជលផល។

លោកបានបង្ហាញនូវការរំពឹងទុកយ៉ាងមុតមាំថាសមាជិកអង្គប្រជុំទាំងអស់ដែលមានវត្តមានក្នុងថ្ងៃនេះនឹងខិតខំប្រឹប្រែងក្នុងការចូលរួមផ្តល់មតិ យោបល់ និងបន្តការជួយគាំទ្រដល់សហគមន៍នេសាទបន្តទៀតក្នុងការរៀបចំរចនាសម្ពន្ធ័គ្រប់គ្រង ការចូលរួមថែរក្សាការអភិរក្ស ការប្រើប្រាស់ធនធានជលផលប្រកបដោយចិរភាព។

នៅចុងបញ្ចប់លោកអភិបាលស្រុកបានសំដែងនូវការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការស្តារកម្ពុជានាយខណ្ឌរដ្ឋបាលជលផលនិងមន្ត្រីជំនាញជលផលទាំងអស់ដែលបានជួយគាំទ្រនិងសម្របសម្រួលក្នុងកិច្ចការងារបង្កើតសហគមន៍នេសាទក្តីឈ្វិតនេះ។ បន្ថែមពីលើនេះទៀតលោកក៏បានសំនូមពរអោយអង្គការស្តារកម្ពុជានិងខណ្ឌរដ្ឋបាលជលផលបន្តកិច្ចសហប្រតិបត្តការនេះបន្តទៀតនៅក្នុងស្រុកកណ្តៀងនេះនិងប្រកាសបើកកម្មវិធីមហាសន្និបាតក្នុងថ្ងៃនេះ។

## ៤.លទ្ធផល

កម្មវិធីមហាសន្និបាតនេះត្រូវបានរៀបចំឡើងដើម្បីជ្រើសរើសគណៈកម្មការសហគមន៍នេសាទ. និងធ្វើការអនុមត័ទៅលើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ។ សហគមន៍នេសាទត្រូវគ្រប់គ្រងដោយគណៈកម្មការមួយដែលធ្វើការសម្រេចចិត្តក្នុងនាមសហគមន៍នេសាទ។

## ៤.១. ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ស្របច្បាប់

គណៈកម្មការសហគមន៍នេសាទត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ដោយសេរីនិងត្រឹមត្រូវដោយមានការសង្កេតការណ៍ពីមន្ត្រីរដ្ឋាភិបាលបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល។ សមាជិកគណៈកម្មការសហគមន៍ដែលបានត្រៀមឈរឈ្មោះបោះឆ្នោតមានចំនួន១៥រូប ក្នុងនោះមានស្ត្រីចំនួន៣រូប និងមានការចូលរួមពីប្រជាពលរដ្ឋក្នុងភូមិក្តីឈ្វិតទាំងមូលចំនួន១០៥នាក់។ ជាលទ្ធផលគណៈកម្មការសហគមន៍នេសាទនៃសហគមន៍ក្តីឈ្វិតមានចំនួន១១រូប ក្នុងនោះស្ត្រីចំនួន១រូបផងដែរ ។ លទ្ធផលនេះបានទទួលនូវការពេញចិត្តពីសំណាក់សមាជិកអង្គប្រជុំទាំងមូល ជាពិសេសប្រជាពលរដ្ឋនិងបេក្ខជនដែលជាប់ឆ្នោត។

*សូមអានបន្ថែមលើបញ្ជីឈ្មោះអ្នកឈរឈ្មោះបោះឆ្នោត បញ្ជីឈ្មោះគណៈកម្មការរាប់សន្លឹកឆ្នោត បញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោត និងបញ្ជីឈ្មោះប្រជាពលរដ្ឋ និងអ្នកចូលរួមទាំង១១០រូបដែលភ្ជាប់ជាមួយ។*

## ៤.២.ការអនុម័តទៅលើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

បន្ទាប់ពីសម្របសម្រួលក្នុងការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍ហើយមន្ត្រីជលផលនិងបុគ្គលិកអង្គការស្តារកម្ពុជាបានសម្របសម្រួលលើការប្រជុំអនុម័តលើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនៃសហគមន៍នេសាទ។ កិច្ចពិភាក្សានេះទទួលបាននូវការជួយចូលរួមពិភាក្សាយ៉ាងផុលផុសពីសំណាក់ប្រជាពលរដ្ឋក្នុងការសម្រេចលើបទបញ្ជាផ្ទៃក្នុងយចំនួនដែលសំខាន់ៗសំរាប់សមាជិកសហគមន៍នេសាទទាំងអស់ដែលអាចនិយាយបានថាកិច្ចពិភាក្សានេះទទួលបាននូវលទ្ធផលល្អប្រសើរគួរទីពេញចិត្ត។

*(សូមអានឯកសារពេញលេញលើលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទក្តីឈ្វិត)*

## ៤.៣. ការពិភាក្សាអនុម័តលើផែនទីដែននេសាទនិងតំបន់អភិរក្សសហគមន៍

ក្រោមការពិភាក្សាយ៉ាងស៊ីជំរៅរបស់នាយរងខណ្ឌរដ្ឋបាលជលផលមន្ត្រីជំនាញលើ GPS និងផែនទីបានបង្ហាញនូវលទ្ធផលមួយដែលមានការទទួលស្គាល់ពីសំណាក់អាជ្ញាធរមូលដ្ឋានស្ថាប័នពាក់ពន្ធ័និងបន្តរៀបចំអោយចេញជាផែនទីសហគមន៍នេសាទមួយយ៉ាងត្រឹមត្រូវនិងត្រូវបិតផ្សាយគ្រប់ទីកន្លែងដែលពាក់ពន្ធ័ដើម្បីអោយមានការទទួលស្គាល់ស្របច្បាប់។

នៅចុងបញ្ចប់នៃកម្មវិធីលោកមេឃុំស្រែស្អុកបានសំដែងនូវចំណាប់អារម្មណ៍និងកោតសរសើរដល់អង្គប្រជុំទាំងមូលដែលសម្រេចបាននូវលទ្ធផលគួរជាទីពេញចិត្ត។ លោកក៏បានមានសំណូមពរដល់សហគមន៍អោយបន្តការចូលរួមសហការណ៍ក្នុងការងារនេះព្រមទាំងបានលើកយកនូវ ច្បាប់ជលផលក៏ដូចជាបទបញ្ជាមួយចំនួនមកបង្ហាញដល់សមាជិក

អង្គប្រជុំទាំងអស់ជាពិសេសប្រជាពលរដ្ឋអោយបានដឹងផងដែរ។

កម្មវិធីមហាសន្និបាតនេះបានបញ្ចប់ទៅដោយទទួលបាននូវលទ្ធផលល្អ ដែលផ្តល់ក្តីសង្ឃឹមនិងមានកិច្ចការមួយចំនួនទៀតដែលត្រូវអនុវត្តបន្តទៀត។

ថ្ងៃ អង្គារ ទី ៣១ ខែកក្កដា ឆ្នាំ ២០១២

បានឃើញនិងឯកភាព

ប្រធានក្រុមប្រឹក្សាឃុំ

អ្នកកត់ត្រា

អ៊ូ ឧស្សាហ៍

មន្ត្រីគម្រោងគ្រប់គ្រងធនធានធម្មជាតិ

## *ឯកសារភ្ជាប់ជាមួយ*

* បញ្ជីឈ្មោះអ្នកឈរឈ្មោះគណៈកម្មការសហគមន៍នេសាទ

| ល.រ | ឈ្មោះ | ភេទ | តួនាទី |
|---|---|---|---|
| ១ | ង៉ក់ គក់ | ប្រុស | ប្រធានសហគមន៍ |
| ២ | ណុច ម៉ឹង | ប្រុស | លេខា |
| ៣ | វិន ខូយ | ប្រុស | សមាជិកល្បាត |
| ៤ | រឿន សៅរិន | ស្រី | បេឡា |
| ៥ | មុំ សិត | ប្រុស | |
| ៦ | ឡាក់ លី | ប្រុស | សមាជិកល្បាត |
| ៧ | ង៉ក់ សូត | ប្រុស | សមាជិកល្បាត |
| ៨ | លាវ ឡាំ | ស្រី | សមាជិកផ្សព្វផ្សាយ |
| ៩ | គិត ធីតា | ស្រី | |
| ១០ | យន យឿង | ប្រុស | ប្រធានល្បាត |
| ១១ | តាប់ ហាន | ប្រុស | |
| ១២ | យ៉ឹង យ៉ុន | ប្រុស | ផ្សព្វផ្សាយ |
| ១៣ | មួន ហ៊ឺ | ប្រុស | អនុប្រធានសហគមន៍ |
| ១៤ | យ៉ឹង ផល | ប្រុស | សមាជិកល្បាត |
| ១៥ | ហូប ហាយ | ប្រុស | |

*បញ្ជីឈ្មោះគណៈកម្មការរៀបចំការបោះឆ្នោត

| ល.រ | គោតនាមនិងនាម | ភេទ | តួនាទី | លេខទូរសព្ទ |
|---|---|---|---|---|
| ១ | លោក ប៊ិន គិត | ប | ប្រធានគណៈកម្មការៀបចំការបោះឆ្នោត | ០៨៨៨០១៥៣៥២ |
| ២ | លោក ហ៊ី វិន | ប | | ០១២១៧៨៨៦៣៣ |
| ៣ | លោក គឹម ធាង | ប | | ០៩២៨២៨៦៩៩ |
| ៤ | លោក មួង រ៉ុន | ប | | ០៨៨៩៣១៧៨៧៦ |
| ៥ | លោក ឡុញ ចូយ | ប | | ០១២៧៦៧២៨២ |

* បញ្ជីវត្តមានអ្នកចូលរួមមហាសន្និបាតទាំងមូល

| ល.រ | ឈ្មោះ | ភេទ | ស្ថាប័ន | តួនាទី | លេខទូរសព្ទ |
|---|---|---|---|---|---|
| ១ | យឹម ទៀង | ប្រ | ខណ្ឌរដ្ឋបាលជលផល | មន្ត្រីជលផល | ០១២៣២១ ១៣៧ |
| ២ | សេង សុងលី | ប្រ | ខណ្ឌរដ្ឋបាលជលផល | មន្ត្រីជលផល | ០៩២២២៦១២៧ |

| | | | | | |
|---|---|---|---|---|---|
| ៣ | ឆាយ មន | ប្រ | ខណ្ឌរដ្ឋបាលជលផល | នាយខណ្ឌ | ០១២៩១៣៥៣១ |
| ៤ | នាង ង៉ែត | ប្រ | ខណ្ឌរដ្ឋបាលជលផល | មន្ត្រីជលផល | ០១៦៧២៣៥៩៥ |
| ៥ | សុខ លីមុត | ប្រ | ស្រុកកណ្ដៀង | អភិបាលស្រុក | ០១២៨៣៥២៨៥ |
| ៦ | សុង ហ៊ឺ | ប្រ | ស្រុកកណ្ដៀង | ប្រជាជន | |
| ៧ | ញ៉ុន ហ៊ីន | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨ | ប៊ិន មាន | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៩ | ហុង យស់ | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១០ | កែន ថាច | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១១ | វ៉ាញ់ ញ៉ាន | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១២ | ជួ រឿន | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១៣ | ហាក់ ស៊ាក | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១៤ | សេង សាន | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១៥ | សេង ជិច | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១៦ | ឃិន យ៉ុង | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១៧ | ឡាក់ លី | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១៨ | មូន ហឺ | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ១៩ | ពឿន ខុន | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ២០ | គង់ សិទ្ធ | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ២១ | ណុច ម៉ឹង | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ២២ | រឿន សៅរិន | ស្រី | ភូមិក្ដីឈ្វិត | អនុភូមិ | |
| ២៣ | ហាយ ហ៊ាត | ស្រី | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ២៤ | ប៊ិន គិត | ប្រ | ភូមិក្ដីឈ្វិត | មេភូមិ | |
| ២៥ | ហ៊ុន ឡាក់ | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ២៦ | វិន សិទ្ធ | ស្រី | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ២៧ | យ៉ឹង យ៉ុន | ប្រ | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ២៨ | ឈឿម ឈុន | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ២៩ | យុត ខា | ស្រី | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៣០ | គឹម ធាង | ប | ភូមិក្ដីឈ្វិត | ក្រុមប្រឹក្សាឃុំ | ០៩២៤២៨៦៩៩ |
| ៣១ | មុត ឃីម | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |

| | | | | | |
|---|---|---|---|---|---|
| ៣២ | ឆុយ ឆេង | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៣៣ | មូង រុន | ប | ភូមិក្តីឈ្វិត | សមាជិកក្រុមប្រឹក្សា | ០៨៨៩៣១៧៨៧៦ |
| ៣៤ | ជា គឹមសឿន | ប | ភូមិក្តីឈ្វិត | ប្រធានឃុំ | ០១២៧៥២៨៣៣ |
| ៣៥ | សុទ្ធ ជន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៣៦ | សេង ណៃគី | ស | ភូមិក្តីឈ្វិត | ប្រជាជន | ០៦០៨៤៦៣២០ |
| ៣៧ | សាំង ហួច | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៣៨ | យ៉ុន សុខា | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៣៩ | ខែម ខុន | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤០ | ខេង ខុំ | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤១ | វ៉ាត វី | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤២ | ប៉ុន វ៉ុន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤៣ | ម៉ៃ កឹង | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤៤ | ហួយ ហាយ | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤៥ | ស៊ុម ប៊ុនធឿន | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤៦ | ឌឿន ខាន់ | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤៧ | ខាន់ សាក់ | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤៨ | ផង លន់ | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៤៩ | ព្រិក ឌិន | ស | ភូមិក្តីឈ្វិត | ខណ្ឌរដ្ឋបាលជលផល សហគមន៍ | |
| ៥០ | រិន គយ | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៥១ | ឃន ថន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៥២ | សេង ផល្លា | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៥៣ | វ៉ាត វ៉ាន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៥៤ | ឡោ សិត | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៥៥ | វ៉ន សុក | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៥៦ | រិនគុយ | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៥៧ | ង៉ួន យាន | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៥៨ | សឿន ស៊ា | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៥៩ | គាន់ គាន | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៦០ | ប៊ិន វើន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |

| | | | | | |
|---|---|---|---|---|---|
| ៦១ | រ៉ែម មាន | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៦២ | រឿន ធី | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៦៣ | រិន វើត | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៦៤ | មាន ចែន | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៦៥ | កាក ខែម | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៦៦ | ប៉ុន វិត | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៦៧ | ហ៊ាន ហ៊ី | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៦៨ | ប៊ិន យឿន | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៦៩ | កឿន គន | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧០ | អំ ស៊ីង | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧១ | ហូយ ហាន | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧២ | ញឹម ន | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧៣ | ឌឹម សំ | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧៤ | ឈី ខ្ទី | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧៥ | គិតធីតា | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧៦ | នី សុណា | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧៧ | យុន ខុន | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧៨ | មួន ឆក់ | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៧៩ | សិត សួយ | ស | ភូមិក្ដីឈ្វិត | សមាជិកសហគមន៍ | |
| ៨០ | ង៉ត់ គក់ | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨១ | ខូ ខេន | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨២ | លាវ ឡាំ | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨៣ | ឈន យ៉ក | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨៤ | ស៊ាម ហាន | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨៥ | ព្រាន ញៀវ | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨៦ | ហ៊ាម ចិន | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨៧ | ឃន ឃឿង | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨៨ | សេន ឈន | ស | ភូមិក្ដីឈ្វិត | ប្រជាជន | |
| ៨៩ | យ៉ឹង យាត | ប | ភូមិក្ដីឈ្វិត | ប្រជាជន | |

| | | | | | |
|---|---|---|---|---|---|
| ៩០ | ហាក់ ឌីម | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៩១ | ផៃ ផុស | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៩២ | ខឿន អូន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៩៣ | ង៉ក់ សូត្រ | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៩៤ | វិន ខូយ | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៩៥ | វិន សុក | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៩៦ | ឈឿង ឈាត | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៩៧ | យាយ គឹម | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៩៨ | ណែម នី | ប | ភូមិក្តីឈ្វិត | ប្រជាជន | |
| ៩៩ | យាយ អ៊ិន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០០ | យាយ គន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០១ | ស៊ាម ឈី | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០២ | ជា យុត | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០៣ | នឹម សុំ | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០៤ | យី នី | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០៥ | ឆាន់ នី | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០៦ | អ៊ំ ស៊ីង | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០៧ | ម៉ិន ងីន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០៨ | ញឹម នាម | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១០៩ | ឆាន់ ម៉ៅ | ស | ភូមិក្តីឈ្វិត | ប្រជាជន | |
| ១១០ | គ្រុយ យន | ស | ភូមិក្តីឈ្វិត | ប្រជាជន | |

ឃុំស្រែស្កុក ថ្ងៃទី...២៧...ខែ....៥.......ឆ្នាំ២០១២

អ្នកកត់ត្រា

# កំណត់ហេតុប្រជុំជាមួយតំណាងសហមន៍និងសហគមន៍
# ស្តីពី
## ការបង្កើសហគមន៍នេសាទនៅ ភូមិក្តីឈ្វិត ឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់

ឆឆឆឆឆ

## ១ ពត៌មានទូរទៅ

ទីកន្លែងប្រជុំ សាលាបឋមសិក្សា ព្រៃត្បាល ក្នុងភូមិក្តីឈ្វិត

កាលបរិច្ឆេទ ថ្ងៃពុធ ទី២៣ ខែឧសភា ឆ្នាំ២០១២

សមាសភាពចូលរួម

| | | |
|---|---|---|
| លោក កាំង | សុវណ្ណ | នាយខណ្ឌរដ្ឋបាលជលផលខេត្តពោធិ៍សាត់(អ្នកសម្របសម្រួល) |
| លោក ពិន | វុទ្ធី | មន្ត្រីសង្កាត់ជលផល(អ្នកសម្របសម្រួល) |
| លោក សៀន | សារ៉េត | បុគ្គលិកអង្គការ |
| លោក គឹម | ផាង | តំណាងអាជ្ញាធរដែនដី |
| លោកស្រីដួង | សម្ផស្ស | នាយិការប្រតិបត្តិរងនៃអង្គការស្តារកម្ពុជា |
| លោក តែ | សុខ ឃឿន | មន្ត្រីសម្របសម្រួលគម្រោងគ្រប់គងធនធានធម្មជាតិ |
| លោកស្រីអ៊ូ | ឧស្សាហ៏ | មន្ត្រីគម្រោងគ្រប់គ្រងធនធានធម្មជាតិ |
| ប្រជាពលរដ្ឋ | | ចំនួន ២៣នាក់(ស្ត្រី៩នាក់)(គណ:កម្មកានិងសហគមន៏) |

គោលបំណង

- ដើម្បីរំលឹកឡើងវិញនូវសកម្មភាពមួយចំនួនដែលបានធ្វើរួចហើយ។
- ដើម្បីរៀបចំធ្វើផែនការយុទ្ធសាស្ត្របន្តទៀតក្រោមការជួយផ្តល់បច្ចេកទេសពីមន្ត្រីជលផល។

## ២ របៀបវារៈនៃកិច្ចប្រជុំ

| ពេលវេលា | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| ៧:៣០-៨:០០ | ការអញ្ជើញមកដកល់របស់អ្នចចូលរួមនិងចុះវត្តមាន | លោក ស្រី អ៊ូ ឧស្សាហ៏ |
| ៨:០០៨:១៥ | ចំណាប់អារម្មណ៏របស់តំណាងអង្គការ | លោក ស្រី ដួង សម្ផស្ស |
| ៨:១៥៨:៣០ | ចំណាប់អារម្មណ៏របស់នាយខណ្ឌរដ្ឋបាលជលផល មន្ត្រីជលផល និងអាជ្ញាធរមូលដ្ឋាន | លោក កាំង សុវណ្ណ<br>លោក ពិន វុទ្ធី<br>លោក |
| ៨:៣០ ៨:៤៥ | ការបង្ហាញពីដំណើរការការបង្កើតសហគមន៏នេសាទ | លោក សៀន សារ៉េត |
| ៨:៤៥ ១០:០០ | ពិភាក្សាផែនការរៀបចំសហគមន៏នេសាទ | លោក តែ សុខ ឃឿន<br>លោក សៀន សារ៉េត<br>លោក ស្រី អ៊ូ ឧស្សាហ៏ |
| ១០:០០១០:៣០ | បង្ហាញលទ្ធផលពិភាក្សា | លោក ស្រី ដួង សម្ផស្ស |

| | ចំណាប់អារម្មណ៍បិទកម្មវិធី | |
|---|---|---|

## ៣ អត្ថន័យនាំទមូលនៃកិច្ចប្រជុំ

*ចំណាប់អារម្មណ៍នាយិការប្រតិបត្តិរងនៃអង្គការស្ដារកម្ពុជា*

ជាកិច្ចចាប់ផ្ដើមនៃអង្គប្រជុំ លោកស្រី ដួង សម្ផស្ស នាយិការប្រតិបត្តិរងនៃអង្គការស្ដារកម្ពុជាបានធ្វើការបង្ហាញសហគមន៍នូវសមាសភាពអ្នកចូលរួមក្នុងកិច្ចប្រជុំ និងគោលបំណងរួមនៃកិច្ចប្រជុំពិភាក្សាក្នុងថ្ងៃនេះ ព្រមទាំងបានគូសបញ្ជាក់ពីគោលបំណងក្នុងការគាំទ្រការងារអង្គការទៀតផង។

*ចំណាប់អារម្មណ៍របស់ លោក កាំង សុវណ្ណ(តំណាងនាយខណ្ឌរដ្ឋបាលជលផលខេត្ត)*

ការបង្កើតសហគមន៍នេសាទនេះ គឺជាការទទួលបាននូវផលប្រយោជន៍យូរអង្វែងនៃការការពារធនធានធម្មជាតិ។ ម្យ៉ាងវិញទៀតសហគមន៍មានតួនាទីក្នុងការការពារនិងថែរក្សាធនធានជលផល និងធនធានធម្មជាតិមិនអោយមានការបាត់បង់។ចំពោះការបង្កើតសហគមន៍នេសាទសហគមន៍ចាំបាច់គឺត្រូវមានទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាននិងជលផលព្រមទាំងស្ថាប័ពាក់ពន្ធ័ផ្សេងៗទៀត។នៅពេលដែលសហគមន៍បានបង្កើតហើយសហគមន៍អាចទាញយកផលប្រយោជន៍ដូចជា អាចទទួលបាននូវការគាំទ្រពីសំណាក់អង្គការផ្សេង ឬម្ចាស់ជំនួយណាមួយដើម្បីធ្វើការអភិវឌ្ឍន៍បន្តទៀតលើតំបន់អភិរក្សនោះ។

*ចំណាប់អារម្មណ៍របស់លោក ពិន វុទ្ធី (មន្ត្រីជលផល)*

ដូចដែលបានទទួលពត៌មាន ឃើញថា មានសហគមន៍ចំនួនពីរបានបង្កើតរួចជាស្រេចហើយ ដោយឡែកនៅតែសហគមន៍ក្ដីឈ្វិតនេះនៅពុំទាន់សម្រេចបានលទ្ធផលនៅឡើយ ដូច្នេះគួរតែផ្ដល់ពត៌មានដល់អាជ្ញាធរជលផល។ ការបង្កើតសហគមន៍នេសាទនេះប្រជាពលរដ្ឋមិនអាចធ្វើតែឯងបានទេ គឺត្រូវមានការចូលរួមនិងសហការពីខាងជលផល។ បន្ថែមពីលើនោះទៀតលោក ពិន វុទ្ធី បានធ្វើការពន្យល់ដល់សហគមន៍ខ្លះៗ នូវបទល្មើសជលផល និងតំបន់អភិរក្ស ។ ចំពោះបទល្មើសជលផល គឺមិនមែនគ្រាន់តែបទល្មើសខាងចាប់ត្រីប៉ុណ្ណោះទេ គឺរាប់ទាំងបទល្មើសពីការកាប់រៀនដីព្រៃលិចទឹកផងដែរ។ ពីព្រោះការកាប់រានដីព្រៃលិចទឹកនេះគឺជាការធ្វើអោយហិនះហោចអស់នូវមច្ឆាជាតិបំផ្លាញកន្លែងផ្ទុកជីវចំរុះនិងជម្រកមច្ឆា។ចំណែកតំបន់អភិរក្សគឺមានន័យថាជាតំបន់ហាមឃាត់និងមិនអោយប្រជាជនចូលនេសាទដើម្បីធ្វើអាជីវកម្មឡើយ។ បទល្មើសនេសាទជាបទល្មើសទី១(ជាប់ពន្ធធនាគាពី៣ទៅ៥ឆ្នាំ) ដូច្នេះសូមសហគមន៍ទាំងអស់គោរពច្បាប់អោយបានខ្ជាប់ខ្ជួន ។ មិនតែប៉ុណ្ណោះសហគមន៍ទាំងអស់គួរតែសហការនិងជួយថែរក្សាធនធានជលផលទាំងអស់គ្នា ត្រូវគិតពីផលប្រយោជន៍យូរអង្វែង។ ហើយដើម្បីសម្រេចបានជោគជ័យក្នុងការបង្កើតសហគមន៍នេសាទប្រជាពលរដ្ឋទាំងអស់ត្រូវមានទំនាក់ទំនងនិងសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជលផល។

*ចំណាប់អារម្មណ៍លោក តំណាងអាជ្ញាធរឃុំ*

លោកបានមានប្រសាសន៍បន្ថែមទៀតទៅលើអត្ថន័យនៃការអភិរក្សតំបន់នេសាទ ហើយដំណើរការនៃការងារនេះគឺពាក់ពន្ធ័នឹងច្បាប់ ។ បឹងស្ពាក់ ជាបឹងដែលមានសក្ដានុពល ដែលអាចបង្កើតជាសហគមន៍នេសាទបានពីព្រោះបឹងនេះមានទឹករហូតទាំងរដូវប្រាំង និងរដូវវស្សា ហើយមានផ្លូវត្រឹមត្រូវដែលអាចធ្វើដំណើរដោយកង់ឬម៉ូតូនិង

គោយន្តបាន។

កិច្ចប្រជុំពិភាក្សានេះ បានប្រព្រឹត្តទៅដោយរលូន និងបញ្ចប់ដោយភាពស្និទស្នាលក្រោមការពិភាក្សា ផ្លាស់ប្តូរយោបល់របស់សហគមន៍ទៅជលផលនិងអង្គការស្តារកម្ពុជា។ ព្រមទាំងបានផ្តល់នូវការផ្តល់ការប្រឹក្សាយោបល់ពីសំណាក់ លោក កាំង សុវណ្ណ និងលោក ពិន វុទ្ធី (មន្ត្រីជំនាញជលផល) ពីវិធីសាស្ត្រនិងឯកសារជំនួនមួយចំនួន។

## ៤ លទ្ធផលពិភាក្សាលើផែនការបង្កើតសហគមន៍នេសាទ

ដោយមានការជួយសម្របសម្រួលផ្នែកបច្ចេកទេសពីសំណាក់ នាយខណ្ឌជលផល មន្ត្រីជលផល និងលោក សឿន សារ៉េត សហគមន៍សម្រេចលទ្ធផលដូចដែលបានរំពឹងទុក និងបានរៀបចំជាផែនការសកម្មភាពដូចខាងក្រោម។

| ជំហ៊ាន | បានធ្វើ | មិនបានធ្វើ | ធ្វើនៅពេលណា | អ្នកចូលរួម |
|---|---|---|---|---|
| ១<br>ដាក់ពាក្យស្នើរសុំបង្កើតសហគមន៍នេសាទ | • បានរៀបចំផ្តិតមេដៃស្នើរសុំពីសហគមន៍រួចហើយ។ហើយក៏បានដាក់ជូនទៅឃុំដើម្បីចុះហត្ថលេខាដែរ ។ ប៉ុន្តែ<br>☞ ពុំទាន់ចុះហត្ថលេខាលើពាក្យស្នើរសុំនះទេដូច្នេះត្រូវពិនិត្យមើលឡើងវិញនៅសាលាឃុំ។ | | • សប្តាហ៏ទី២ខែមិថុនា<br>• សហគមន៍និងគណកម្មការទៅពិនិត្យនៅឃុំ។រួចដាក់ពាក្យស្នើរសុំឡើងវិញ។<br>• ចំពោះទម្រង់ពាក្យស្នើរសុំនិងទាក់ទងទៅខណ្ឌជលផលខេត្ត។ | គណកម្មការសហគមន៏ |
| ២<br>ការប្រមូលពត៌មាន | នឹងពិនិត្យឡើងវិញនៅឃុំជាមួយប្រធានឃុំ | | • សប្តាហ៏ទី២ខែមិថុនា | គណកម្មការសហគមន៏ |
| ៣<br>បង្កើតក្រុមស្ថានិកនិងរៀបចំសមាសភាព | | | • | គណកម្មការសហគមន៏ |
| ៤<br>ចុះបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ | អនុវត្តដូចជំហានទី១ដែរ | | • សប្តាហ៏ទី២ខែមិថុនា | គណកម្មការសហគមន៏ |
| ៥ | ត្រួតពិនិត្យមើលឡើង | | • សប្តាហ៏ទី១ខែកក្កដា | មន្ត្រីជំនាញ |

| | | | | |
|---|---|---|---|---|
| សេចក្តីព្រៀងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | វិញតាមរយៈការប្រជុំជាមួយសហគមន៍ | | | ជលផល<br>ឃុំ គណកម្មការនិងសមាជិកសហគមន៍ |
| ៦<br>សម្របសម្រួលរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មកា | ប្រជុំពិនិត្យសមាសភាពគណកម្មការសហគមន៍ | | • សប្តាហ៍ទី១ខែកក្កដា | មន្ត្រីជំនាញ<br>ជលផល<br>ឃុំ<br>គណកម្មការនិងសមាជិកសហគមន៍ |
| ៧<br>កំណត់ព្រំប្រទល់និងធ្វើផែនទីសហគមន៍នេសាទ | | ✓ | • សប្តាហ៍ទី៣ ខែមិថុនា | គណកម្មការនិងសហគមន៍<br>ជលផលចុះចុចGIS<br>មន្ត្រីសុរិយោដី<br>មន្ត្រីបរិស្ថាន<br>ប្រធានឃុំ |
| ៨<br>ការធ្វើផែនការគ្រប់គ្រង | | ✓ | • សប្តាហ៍ទី៤ ខែកក្កដា | គណកម្មការនិងសហគមន៍<br>ជលផល<br>ប្រធានឃុំ |
| ៩<br>ការរៀបចំចុះកិច្ចសន្យាព្រមព្រៀងកន្លែងនេសាទសហគមន៍ | | ✓ | • ខែកញ្ញា | គណកម្មការនិងសហគមន៍<br>ជលផល<br>ប្រធានឃុំ |
| ១០<br>ប្រកាសស្របច្បាប់ | | | | |

ភ្នំពេញ ថ្ងៃអង្គារទី២៩ ខែឧសភា ឆ្នាំ ២០១២

អ្នកកត់ត្រា

អ៊ូ ឧស្សាហ៍